# សេចក្តីជូនដំណឹងពីអត្ថប្រយោជន៍ដែលមាននៅក្រោម M.G.L. ជំពូក 175M
# ច្បាប់ឈប់សម្រាកដោយហេតុផលគ្រួសារ និងជំងឺដោយមានប្រាក់ឈ្នួល

## ចាប់ផ្តើមនៅថ្ងៃទី 1 ខែតុលា ឆ្នាំ 2019៖

- និយោជកនឹងកាត់យកវិភាគទានប្រាក់បៀវត្សរ៍ពីប្រាក់ឈ្នួល ឬប្រាក់ចំណូលរកបាន របស់បុគ្គលដែលត្រូវបានរ៉ាប់រងដើម្បីផ្គត់ផ្គង់មូលនិធិដល់អត្ថប្រយោជន៍ PFML។

## ចាប់ផ្តើមនៅថ្ងៃទី 1មករា ឆ្នាំ 2021៖

- បុគ្គលដែលត្រូវបានរ៉ាប់រងអាចនឹងមានសិទ្ធិសក្តិសមទទួលបានរហូតដល់ 20 សប្តាហ៍នៃច្បាប់ឈប់សម្រាកដោយមូលហេតុជំងឺដោយមានប្រាក់ឈ្នួលនៅក្នុងឆ្នាំអត្ថប្រយោជន៍ ប្រសិនបើពួកគេមានស្ថានភាពសុខភាពធ្ងន់ធ្ងរដែលធ្វើឲ្យពួកគេបាត់បង់សមត្ថភាពពីការងារ។
- បុគ្គលដែលត្រូវបានរ៉ាប់រងអាចនឹងមានសិទ្ធិសក្តិសមទទួលបានរហូតដល់ 12 សប្តាហ៍នៃច្បាប់ឈប់សម្រាកដោយសារមូលហេតុគ្រួសារនៅក្នុងឆ្នាំអត្ថប្រយោជន៍ទាក់ទងនឹងកំណើតកូន ការសុំកូនមកចិញ្ចឹម ឬការ ដាក់ឲ្យទទួលធ្វើការចិញ្ចឹមបីបាច់ថែរក្សាកូន ឬដោយសារតែភាពបន្ទាន់ចាំបាច់ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់កើតចេញមកពីការពិតដែលថាសមាជិកក្រុមគ្រួសារកំពុងមានភារកិច្ចសកម្ម ឬត្រូវបានជូនដំណឹង ពីការហៅឲ្យចូលបម្រើភារកិច្ចសកម្មដែលប្រុងនឹងកើតមាននៅក្នុងកងកម្លាំងប្រដាប់អាវុធ។
- បុគ្គលដែលត្រូវបានរ៉ាប់រងមានសិទ្ធិសក្តិសមនឹងទទួលបានរហូតដល់ 26 សប្តាហ៍នៃច្បាប់ឈប់សម្រាកដោយសារមូលហេតុគ្រួសារដោយមានប្រាក់ឈ្នួលនៅក្នុងឆ្នាំអត្ថប្រយោជន៍ដើម្បីថែទាំសមាជិកក្រុមគ្រួសារដែល ជាសមាជិកសេវាកម្មដែលត្រូវបានរ៉ាប់រងដែលមានស្ថានភាពសុខភាពធ្ងន់ធ្ងរ។

## ចាប់ផ្តើមនៅថ្ងៃទី 1កក្កដា ឆ្នាំ 2021៖

- បុគ្គលដែលត្រូវបានរ៉ាប់រងអាចនឹងមានសិទ្ធិសក្តិសមទទួលបានរហូតដល់ 12 សប្តាហ៍នៃច្បាប់ឈប់សម្រាកដោយសារមូលហេតុគ្រួសារដោយមានប្រាក់ឈ្នួលដើម្បីថែទាំសមាជិកក្រុមគ្រួសារដែលមានស្ថានភាពសុខភាពធ្ងន់ធ្ងរ។

បុគ្គលដែលត្រូវបានរ៉ាប់រងមានសិទ្ធិសក្តិសមទទួលមិនលើសពីចំនួនសរុប 26 សប្តាហ៍បូកបញ្ចូលគ្នាទាំងអស់ នៃច្បាប់ឈប់សម្រាកដោយសារមូលហេតុគ្រួសារ និងជំងឺនៅក្នុងឆ្នាំអត្ថប្រយោជន៍តែមួយ។

## តើនរណាជាបុគ្គលដែលត្រូវបានរ៉ាប់រងនៅក្រោមច្បាប់?



ជាទូទៅ បុគ្គលិកធ្វើការមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាបុគ្គលដែលត្រូវបានរ៉ាប់រង ហើយអាចនឹងមានសិទ្ធិសក្តិមសទទួលបានច្បាប់ឈប់សម្រាកដោយសារមូលហេតុគ្រួសារ និងជំងឺប្រសិនបើ៖

- គាត់ត្រូវបានបង់ទូទាត់ប្រាក់ឈ្នួលជូនដោយនិយោជករដ្ឋម៉ាសាឈូសេត ឬ
- គាត់ស្នាក់នៅក្នុងរដ្ឋម៉ាសាឈូសេត ហើយត្រូវបានបង់ប្រាក់ខែជូនសម្រាប់សេវាកម្មកិច្ចសន្យាដោយអង្គភាពនៅរដ្ឋម៉ាសាឈូសេតដែលត្រូវបានតម្រូវទាមទារឲ្យរាយការណ៍ការបង់ទូទាត់សម្រាប់សេវាកម្មនៅលើទម្រង់បែបបទ IRS 1099-MISC សម្រាប់លើសពី 50 ភាគរយនៃកងកម្លាំងពលកម្មរបស់ខ្លួន ឬ
- គាត់ជាបុគ្គលដែលធ្វើការរកស៊ីខ្លួនឯងដែលស្នាក់នៅក្នុងរដ្ឋម៉ាសាឈូសេត ហើយជ្រើសរើសចូលរួមនៅក្នុងកម្មវិធី។

## ការការពារការងារ

ជាទូទៅ និយោជិតម្នាក់ដែលបានប្រើច្បាប់ឈប់សម្រាកដោយហេតុផលគ្រួសារ ឬជំងឺត្រូវតែត្រូវបានស្តារត្រឡប់ទៅកាន់ដំណែងពីមុន ឬទៅកាន់តំណែងសមមូលរបស់និយោជិតដោយមានស្ថានភាព ប្រាក់ខែ អត្ថប្រយោជន៍ក្នុងការងារ កិត្តិយសនៃរយៈពេលដែលបានបម្រើផ្តល់សេវាកម្ម និងអតីតភាពនៃការងារដដែលគិតត្រឹមថ្ងៃច្បាប់ឈប់សម្រាក។

*ការការពារការងារទាំងនេះមិនអនុវត្តទៅលើអ្នកជាប់កិច្ចសន្យាទេ។*

## អត្ថប្រយោជន៍ប្រចាំសប្តាហ៍

ដើម្បីផ្គត់ផ្គង់មូលនិធិដល់អត្ថប្រយោជន៍ PFML និយោជកនឹងកាត់យកវិភាគទានប្រាក់បៀវត្សរ៍ពីប្រាក់ឈ្នួល ឬប្រាក់ចំណូលរកបានដទៃទៀតរបស់ បុគ្គលដែលត្រូវបានរ៉ាប់រង ដោយចាប់ផ្តើមនៅថ្ងៃទី 1 ខែតុលា ឆ្នាំ 2019។ បុគ្គលដែលត្រូវបានរ៉ាប់រងអាចដាក់ពាក្យសុំអត្ថប្រយោជន៍បានដោយចាប់ផ្តើមនៅខែមករា ឆ្នាំ 2021 តាមរយៈផ្នែកច្បាប់ឈប់សម្រាកដោយសារមូលហេតុគ្រួសារ និងជំងឺ។ ប្រាក់ចំណូលរកបានជាមធ្យមប្រចាំសប្តាហ៍របស់បុគ្គលដែលត្រូវបានរ៉ាប់រងនឹងកំណត់ចំនួនអត្ថប្រយោជន៍របស់គាត់ សម្រាប់អត្ថប្រយោជន៍ប្រចាំសប្តាហ៍អតិបរមារហូតដល់ $850 ។

## គ្មានការសងសឹក ឬរើសអើង

- វាខុសនឹងច្បាប់សម្រាប់និយោជកក្នុងការរើសអើង ឬសងសឹកប្រឆាំងនឹងនិយោជិតចំពោះការប្រើប្រាស់សិទ្ធិណាមួយដែលពួកគេមានសិទ្ធិសក្តិសមទទួលបាននៅក្រោមច្បាប់។
- និយោជិត ឬអតីតនិយោជិតដែលត្រូវបានរើសអើង ឬសងសឹកប្រឆាំងចំពោះការប្រើប្រាស់សិទ្ធិនៅក្រោមច្បាប់ អាចនឹង មិនលើសពីបីឆ្នាំក្រោយពីការបំពារបំពានកើតឡើង ដាក់បណ្តឹងរដ្ឋប្បវេណីនៅតុលាការជាន់ខ្ពស់ ហើយអាចនឹងមានសិទ្ធិសក្តិសមទទួលបានការសងជំងឺចិត្តដែលមានចំនួនច្រើនស្មើនឹងបីដងនៃប្រាក់ឈ្នួលដែលបាត់បង់របស់ខ្លួន។

## គម្រោងឯកជន

ប្រសិនបើនិយោជកផ្តល់ជូននិយោជិតនូវច្បាប់ឈប់សម្រាកដោយមូលហេតុគ្រួសារ ដោយមូលហេតុជំងឺ ឬទាំងពីរដោយមានប្រាក់ឈ្នួល ជាមួយអត្ថប្រយោជន៍ ដែលយ៉ាងហោចណាស់មានភាពសប្បុរសដូចអត្ថប្រយោជន៍ដែលត្រូវបានចែងនៅក្រោមច្បាប់ នោះនិយោជកអាចនឹងដាក់ពាក្យសុំការលើកលែង ពីការបង់វិភាគទាន បាន។ និយោជិតបន្តត្រូវបានការពារពីការរើសអើង និងការសងសឹកនៅក្រោមច្បាប់ សូម្បីតែនៅពេលនិយោជកជ្រើសរើសទៅកាន់ការផ្តល់អត្ថប្រយោជន៍ច្បាប់ ឈប់សម្រាកដោយមានប្រាក់ឈ្នួលតាមរយៈគម្រោងឯកជនក៏ដោយ។



**ប្រសិនបើអ្នកមានសំណួរ ឬកង្វល់អំពីសិទ្ធិច្បាប់ឈប់សម្រាកដោយមូលហេតុគ្រួសារ និងជំងឺដោយមានប្រាក់ឈ្នួលរបស់អ្នក សូមទាក់ទង៖**

MassPFML@Mass.gov ឬចូលទៅកាន់៖ mass.gov/DFML

សេចក្តីត្រូវតែបិទប្រកាសនៅក្នុងកន្លែងដែលលេចធ្លោ នៅលើបរិវេណរបស់និយោជក។